គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS
HROTP- IDA- KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP - PJJ - VIGILANCE
#09, St 330, Sangkat Boeung Keng Kang 3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 351 415 E-mail: chrac@forum.org.kh

# សេចក្តីថ្លែងការណ៍

## សង្គមស៊ីវិលអំពាវនាវឱ្យមានការស៊ើបអង្កេតជនសង្ស័យបន្ថែមដោយអង្គជំនុំជម្រះវិសាមញ្ញ

*ភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩*

ឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ដែលបានចេញដោយការិយាល័យសហព្រះរាជអាជ្ញាកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០៨ និងថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្ស (CHRAC) ដែលជាសម្ព័ន្ធអង្គការ-សមាគមសមាជិកចំនួន២១ សូមអំពាវនាវដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ដំណើរការទៅដោយឯករាជ្យ និងអនុវត្តន៍អាណត្តិរបស់ខ្លួន ដោយធ្វើការស៊ើបអង្កេតជនសង្ស័យបន្ថែមទៀត ដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងជឿជាក់ថា បរាជ័យណាមួយ នឹងធ្វើឱ្យជះឥទ្ធិពលប៉ះពាល់សាលាក្តី និងកេរ្តិ៍តំណែលរបស់សាលាក្តីនេះដែរ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមបានសុខចិត្តទទួលយករួចទៅហើយនូវអាណត្តិដែលមានកំរិតរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយសារទទួលស្គាល់នូវភាពពិត នៃយុត្តិធម៌អន្តរកាល ដូចនេះ គេមិនសុខចិត្តទទួលយកនូវការបរាជ័យណាមួយរបស់តុលាការនេះក្នុងការមិនអនុវត្តន៍នូវអំណាចយុត្តាធិការ និងការទទួលខុសត្រូវរបស់តុលាការឱ្យបានពេញលេញនោះឡើយ ។

យោងទៅតាមសេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាចេញផ្សាយថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាជាតិ ចាត់ទុកថា ការស៊ើបអង្កេតបន្ថែមទៀតមិនគួរធ្វើឡើងទៅលើជនសង្ស័យបន្ថែមឡើយ ដោយសារពិចារណាទៅលើបីចំនុច គឺ: ទី១- សេចក្តីត្រូវការឱ្យមានស្ថេរភាព និងការផ្សះផ្សារជាតិ, ទី២- ស្មារតីនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (ហៅថា “កិច្ចព្រមព្រៀង”) និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទី៣-ពេលវេលា និងថវិកាដែលមានសំរាប់តុលាការនៅមានកំរិត ។ យើងមិនចង់ចាត់ទុកថា កត្តាទាំងអស់នេះ នឹងបង្កការរាំងដល់ការស៊ើបអង្កេតទៅលើជនសង្ស័យបន្ថែមនោះឡើយ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌ និងជួយផ្សះផ្សារជាតិ ដោយការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក៏ត្រូវរៀបចំយ៉ាងជាកលាក់ក្នុង

ការធានាថា សេចក្ដីត្រូវការយុត្តិធម៌មិនមានសមតុល្យនឹងសេចក្ដីត្រូវការស្ថេរភាពសង្គម និង ការផ្សះផ្សារជាតិ។ ផ្ទុយនឹងការព្រួយបារម្ភពីមុនៗ ការចាប់ខ្លួន និងការប្រព្រឹត្តចំពោះជនត្រូវចោទនាពេលបច្ចុប្បន្នទាំង ៥ នាក់ មិនបង្កឱ្យមានបញ្ហាអស្ថេរភាព ហើយក៏ មិនមានភស្តុតាងដែលជឿជាក់ថា ការកាត់សេចក្ដីជនសង្ស័យបន្ថែមដែលមានចំនួនប្រហាក់ប្រហែលគ្នានេះ នឹងអាចប៉ះពាល់ដល់ស្ថេរភាពរបស់ប្រទេសកម្ពុជា ឬការផ្សះផ្សារជាតិឡើយ។ កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការ បង្កើតអង្គជំនុំជម្រះវិសាមញ្ញ គឺជាអ្នកធានារក្សានូវសេចក្ដីត្រូវការស្ថេរភាព និងការផ្សះផ្សារជាតិទាំងនេះ និងមិនមែនមន្ត្រីម្នាក់ៗរបស់អង្គជំនុំជម្រះឡើយ។ យើងយល់ថា សេចក្ដីត្រូវការយុត្តិធម៌ ត្រូវតែថ្លឹងថ្លែងជាមួយនឹងបញ្ហាស្ថេរភាពទាំងនេះ និងដើម្បីជំរះការព្រួយបារម្ភណាមួយនៅក្នុងប្រទេសកម្ពុជាទាក់ទិននឹងសកម្មភាពណាមួយប្រឆាំងទល់នឹងបុគ្គលអតីតខ្មែរក្រហម យើងក៏សូមអំពាវនាវឱ្យសាលាក្ដីឱ្យធ្វើដំណើរឆ្ពោះទៅមុខ ជាលើកចុងក្រោយ និងមានលក្ខណៈច្បាស់លាស់ចំពោះជនសង្ស័យដែលនៅសេសសល់ទាំងអស់។ ការនេះ នឹងជួយធានាថា បុគ្គលអតីតខ្មែរក្រហមផ្សេងទៀត ដែលមិនមែនជាកម្មវត្ថុនៃដំណើរការនីតិវិធីស៊ើបអង្កេតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដឹងថា គេមិនចាំបាច់មានការភ័យខ្លាច និងក៏ធានាផងដែរថា ការសហការរបស់គេ នឹងត្រូវបានធានាសន្តិសុខសុវត្ថិភាពជូនពេញលេញ។

យើងជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញ មិនគួរកំរិតខ្លួនឯងលើសពីការដាក់កំហិតនូវយុត្តិធិការ ក្នុងការចោទប្រកាន់ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះទេ។ កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចែងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញ នឹងនាំយកតែមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវជាន់ខ្ពស់ចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងរបបនោះ តែប៉ុណ្ណោះ។ ដោយសារថា សហព្រះរាជអាជ្ញា បានកំណត់ជនសង្ស័យដែលត្រូវស៊ើបអង្កេតបន្ថែមទាំងនោះ ថាជនដែលទទួលខុសត្រូវជាន់ខ្ពស់ចំពោះឧក្រិដ្ឋកម្ម ដូចនេះ យើងចាត់ទុកថា ជារឿងសមស្របដែលអង្គជំនុំជម្រះវិសាមញ្ញបន្តធ្វើការចោទប្រកាន់បន្ថែមទៀត ទៅលើជនសង្ស័យទាំងនោះ។

យើងមិនជឿថា សាលាក្ដីគួរតែកំរិតយុត្តាធិការ ក្នុងការចោទប្រកាន់តែទៅលើមនុស្ស ៥នាក់ នោះឡើយ។ ប្រសិនបើមានការសង្ស័យគួរឱ្យជឿជាក់ថា ជនណាមួយនឹងមានពិរុទ្ធភាពនៅក្រោមយុត្តាធិការរបស់អាណត្តិ នៃសាលាក្ដី គេគួរតែចាប់ផ្ដើមធ្វើការស៊ើបអង្កេតដោយមិនមានការពន្យាពេល។ ចំណាត់ការបែបនេះ នឹងឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវស្មារតីនៃកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

លើសពីនេះទៅទៀត យើងក៏ចាត់ទុកថា ការបញ្ចប់អាណត្តិរបស់សាលាក្ដីដោយជោគជ័យ និងដោយពេញលេញ គួរតែជាអាទិភាពច្រើនជាង ការពិចារណារយៈពេលខ្លីទៅលើថវិកា និងពេលវេលា។ ប្រសិនបើនៅចុងបញ្ចប់នៃអង្គជំនុំជម្រះវិសាមញ្ញ ហើយក្រៅពីការចំណាយដ៏ច្រើនក្នុងការបង្កើត និងដំណើរការរបស់ខ្លួន សាលាក្ដីខកខានមិនបានចោទប្រកាន់ទៅលើបុគ្គលជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋទាំងអស់ដែលនៅរស់នោះទេ

នោះ គឺថា ការចំណាយទាំងអស់នេះ នឹងត្រូវបានគេមើលឃើញថាបានខ្ជះខ្ជាយយ៉ាងសំបើមណាស់។ យើងជឿជាក់ថា សាលាក្តីនេះ មានលទ្ធភាពក្នុងការធ្វើការស៊ើបអង្កេត និងកាត់សេចក្តីទៅលើជនសង្ស័យបន្ថែមទៀត ហើយក៏ជឿជាក់ថា ម្ចាស់អំណោយក៏នឹងមានឆន្ទៈគាំទ្រសកម្មភាពទាំងនេះដែរ ប្រសិនបើមានតំរូវការឱ្យមានធនធានគ្រប់គ្រាន់ចាំបាច់សំរាប់ឱ្យសាលាក្តីសំរេចបានគោលបំណងរបស់ខ្លួននោះ។

ក្នុងផលប្រយោជន៍យុត្តិធម៌ ការផ្សះផ្សារជាតិ និងស្ថេរភាពនាពេលអនាគត យើងចាត់ទុកថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ត្រូវតែនាំយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ប្រសិនបើគ្មានការចោទប្រកាន់បន្ថែមទៀតទេ នោះ អង្គជំនុំជម្រះវិសាមញ្ញ បរាជ័យក្នុងការផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋកម្ពុជា និងបំផ្លាញនូវកិច្ចខិតខំប្រឹងប្រែងផ្សះផ្សារដ៏ពិតប្រាកដដែរ។ យើងមានការព្រួយបារម្ភថា កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធិផលរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រជាពលរដ្ឋកម្ពុជា និងសហគមន៍អន្តរជាតិ ក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ គ្រាន់តែជាការចំណាយខ្ជះខ្ជាយទៅវិញ ប្រសិនបើសាលាក្តីនេះ គ្រាន់តែត្រូវបានគេមើលឃើញថា បំពេញបេសកកម្មរបស់ខ្លួនបានតែមួយផ្នែកនោះ។

យើងក៏សូមជំរុញដល់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ មេត្តាធានាថា អង្គជំនុំជម្រះវិសាមញ្ញដំណើរការទៅដោយឯករាជ្យ និងដោយមិនមានការជ្រៀតជ្រែកនយោបាយ និងគាំទ្រសាលាក្តីនេះឱ្យបានពេញលេញក្នុងការបំពេញបេសកកម្មរបស់ខ្លួន។


**សំរាប់ព័ត៌មានលំអិត សូមទំនាក់ទំនងៈ**

| | | |
|---|---|---|
| លោក **សុក សំអឿន** | ប្រធានសំរបសំរួល CHRAC/នាយកប្រតិបត្តិ CDP | លេខៈ ០១២ ៩០១ ១១៩ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) | លេខៈ ០១៦ ៨៨០ ៥០៩ |
| កញ្ញា **សេង ធារី** | នាយិកាប្រតិបត្តិមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD) | លេខៈ ០១២ ២២២ ៥៥២ |
| លោក **ហង្ស ឆាយា** | នាយកប្រតិបត្តិវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) | លេខៈ ០១២ ៩៧៥ ៨៨៣ |